**សេចក្តីព្រាង**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ

# (២០២៥-២០២៩)

# ស្រុកទឹកឈូ ខេត្តកំពត

បានទទួលការអនុម័តពីក្រុមប្រឹក្សាស្រុក

ក្នុងកិច្ចប្រជុំវិសាមញ្ញលើកទី ៤ នាថ្ងៃទី  ខែ ឆ្នាំ ២០២៥

# មាតិកាសៀវភៅផែនការអភិវឌ្ឍន៍ស្រុក


សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ស្រុករយៈពេលប្រាំឆ្នាំ........................................i

អារម្ភកថា................................................................................................................iii

សេចក្តីផ្តើម ...............................................................................................................iv

ផែនទីស្រុក.................................................................................................................v

**ជំពូកទី១ ៖ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច**.............................................................. ១

១.១ សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច.......................................................... ១

១.១.១ ស្ថានភាពភូមិសាស្ត្រ...................................................................................... ១

១.១.២. សេចក្តីសង្ខេបព័ត៌មាន និងទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច.......................................... ១

១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម................................................................... ៤

១.២.១. ស្ថានភាពសេដ្ឋកិច្ច...................................................................................... ៤

១.២.២. ស្ថានភាពសង្គមកិច្ច...................................................................................... ៩

១.២.៣. ស្ថានភាពនៃការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំ ការប្រែប្រួលអាកាសធាតុ..... ១៥

១.២.៤. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សារធារណៈ ................. ១៧

**ជំពូកទី២ ៖ ក្របខ័ណ្ឌអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា**.............................២១

២.១. ចក្ខុវិស័យអភិវឌ្ឍន៍..........................................................................................២២

២.២. គោលបំណងអភិវឌ្ឍន៍........................................................................................ ២៣

២.៣. គោលដៅអភិវឌ្ឍន៍........................................................................................... ២៣

២.៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍........................................................................................ ២៣

២.៤.១. យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច ......................................................................... ២៣

២.៤.២. យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច.........................................................................២៤

២.៤.៣. យុទ្ធសាស្ត្រអភិវឌ្ឍន៍ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹង ការប្រែប្រួលអាកាសធាតុ..................................................................................២៥

២.៤.៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍ការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ..........២៦

២.៥. តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ស្រុក.......................................................................... ២៧

**ជំពូកទី៣ ៖ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ......................................................................៤០**

៣.១. ក្របខ័ណ្ឌវិនិយោគ ............................................................................................................៤២

៣.២. ក្របខ័ណ្ឌផ្តល់សេវា.............................................................................................................. ៦២

៣.៣. ការដាក់ចេញលិខិតបទដ្ឋានគតិយុទ្ធនានា.................................................................................. ៦៦

៣.៤. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម..................... ..................................................................៦៧

**ជំពូកទី៤ ÷ ក្របខ័ណ្ឌតាមដាន និងវាយតម្លៃផែនការអភិវឌ្ឍន៍..................................................................៦៨**

៤.១. យន្តការតាមដាន និងវាយតម្លៃ ........................................................................................... ៦៩

៤.២. វិធីសាស្ត្រតាមដាន និងវាយតម្លៃ........................................................................................ ៦៩

៤.៣. សូចនាករតាមដាន និងវាយតម្លៃ ........................................................................................ ៦៩

**ឧបសម្ព័ន្ធ .........................................................................................................................................**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលស្រុកទឹកឈូ**
លេខ:   /២៤ ស.ស.រ

# សេចក្តីសម្រេច
# ស្តីពី
# ការដាក់ឲ្យប្រើប្រាស់សៀវភៅផែនការអភិវឌ្ឍន៍ស្រុក

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្របក. ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពី តួនាទីភារកិច្ចនិងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក។
- បានឃើញអនុក្រឹត្យលេខ ២១៩ អនក្របក. ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្របក. ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ២០១០ ស្តីពីការកែសម្រួលមាត្រា ១២ នៃអនុក្រឹត្យលេខ ២១៩ អនក្របក. ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការ កសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- បានឃើញប្រកាសអន្តរក្រសួងនៃក្រសួងមហាផ្ទៃ និង ក្រសួងផែនការលេខ ២៤១៧ ប្រកចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០១០ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញប្រកាសអន្តរក្រសួងនៃក្រសួងមហាផ្ទៃ និង ក្រសួងផែនការលេខ ៣៥១៤ ប្រកចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលប្រការ១នៃប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ៣៧៧ អនក្រ.តក ចុះថ្ងៃព្រហស្បត្តិ៍ ១៥កេចខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០២៤ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកទឹកឈូ។
- យោងតាមស្មារតីនៃកិច្ចប្រជុំវិសាមញ្ញលើកទី របស់ក្រុមប្រឹក្សាស្រុក អាណត្តិទី៤ ថ្ងៃទី ខែ តុលា ឆ្នាំ ២០២៥

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឲ្យប្រើប្រាស់សៀវភៅផែនការអភិវឌ្ឍន៍ស្រុក ( ២០២៥-២០២៩ ) របស់ស្រុកទឹកឈូ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាស្រុក នាកិច្ចប្រជុំវិសាមញ្ញលើកទី៤ ថ្ងៃទី ខែ ឆ្នាំ ២០២៥ ។

**ប្រការ ២.-**

គណៈអភិបាលស្រុកទឹកឈូ ត្រូវចាត់ចែងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍នេះ ដល់ប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលស្រុកទឹកឈូ ។

គណៈអភិបាលស្រុកទឹកឈូ ត្រូវចាត់ចែងសម្របសម្រួល និងកៀរគរធនធាននានា ក្នុងការ អនុវត្តផែនការអភិវឌ្ឍន៍នេះ ប្រកបដោយការចូលរួម មានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៣.-**

គណៈអភិបាលស្រុកទឹកឈូ ត្រូវរៀបចំយន្តការនិងប្រព័ន្ធសម្រាប់ការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នេះដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធនានាដើម្បី បង្កើនប្រសិទ្ធភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍ ។

គណៈអភិបាលស្រុកទឹកឈូ រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នេះនិងរាយការណ៍ជូនអង្គប្រជុំក្រុមប្រឹក្សាស្រុកទឹកឈូអំពី វឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍នេះ ទៅតាមកាលកំណត់ ។

គណៈអភិបាលស្រុកទឹកឈូ ត្រូវរៀបចំ និងដាក់ជូនក្រុមប្រឹក្សាស្រុក អំពីរបាយការណ៍ ប្រចាំឆ្នាំស្តីពីការអនុវត្តផែនការអភិវឌ្ឍន៍នេះ ។

**ប្រការ ៤.-**

គណៈអភិបាលស្រុកទឹកឈូ ត្រូវធ្វើការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នេះនៅពាក់កណ្តាល អាណត្តិ និង ចុងអាណត្តិរបស់ក្រុមប្រឹក្សាស្រុក ដើម្បីវាយតម្លៃអំពីលទ្ធផលសម្រេចបានធៀបនឹងគោលដៅ និងគោលបំណង ដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ស្រុក ។

**ប្រការ ៥.-**

គណៈអភិបាល ការិយាល័យ និងអង្គភាពពាក់ព័ន្ធ ទាំងអស់ក្នុង ស្រុកទឹកឈូត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ១៤រោច ខែចេត្រ ឆ្នាំ រោង ឆស័ក ព.ស២៥៦៨
ទឹកឈូ,ថ្ងៃទី ខែ មេសា ឆ្នាំ២០២៥
**ប្រធានក្រុមប្រឹក្សាស្រុក**

# អារម្ភកថា

បន្ទាប់ពីបានចងក្រងរៀបចំផែនការអភិវឌ្ឍន៍ស្រុក រយៈពេលប្រាំឆ្នាំ( ២០២៥-២០២៩ )រួចមក ស្រុកបានបន្តយកចិត្តទុកដាក់រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ស្រុក ដែលជាឯកសារមូលដ្ឋាន សម្រាប់បម្រើការអភិវឌ្ឍន៍តាមវិស័យនីមួយៗឱ្យមានភាពកាន់តែប្រសើរ ។ជាមួយគ្នានេះក្រុមប្រឹក្សាស្រុក ក៏បានផ្តល់ឱកាសឱ្យមានការចូលរួមផ្ទាល់នូវការដាក់បញ្ចូលអំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចនិងការលើកសំណើគម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលមកពីបណ្តាឃុំ ការិយាល័យ អង្គភាពពាក់ព័ន្ធ ជុំវិញស្រុក  អង្គការសង្គមស៊ីវិល វិស័យឯកជនទៅក្នុងកិច្ចដំណើរការនៃការរៀបចំកម្មវិធីវិនិយោគបីឆ្នាំ រំកិលរបស់ស្រុកផងដែរ ។ កម្មវិធីវិនិយោគបីឆ្នាំរំកិលនេះបានបង្កើតឡើង ស្របទៅនឹងគោលការណ៍ ណែនាំផ្នែកគោលនយោបាយ និងក្របខ័ណ្ឌអភិវឌ្ឍន៍ស្រុក  ដែលជាឧបករណ៍សម្រាប់ជំរុញការអនុវត្ត ឱ្យកាន់តែមានប្រសិទ្ធភាព ដល់រដ្ឋបាលស្រុក ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច  សង្គមកិច្ចក្នុងមូលដ្ឋាននិងលើកកម្ពស់គុណភាពសេវាសាធារណៈឱ្យខិតជិតប្រជាពលរដ្ឋសំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រនិង លើកកម្ពស់គុណភាពជីវភាពរស់នៅប្រកបដោយសុខុមាលភាព និងសុវត្ថិភាពក្នុងស្រុកទាំងមូល ។

ក្នុងនាមក្រុមប្រឹក្សាស្រុកអាណត្តិទី៤  ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបំផុតគណៈអភិបាលស្រុកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសស្រុកគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារស្រុកក្រុមការងារកសាងផែនការស្រុក មេឃុំ ការិយាល័យ អង្គភាពនានាជុំវិញស្រុក អង្គការសង្គមស៊ីវិល វិស័យឯកជននិងអ្នកពាក់ព័ន្ធនានាក្នុងស្រុក  ដែលបានចូលរួមយ៉ាង  សកម្មក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ស្រុក  កម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក រហូតបានសម្រេច លទ្ធផលនាពេលនេះ ។

ជំនួសមុខឱ្យក្រុមប្រឹក្សាស្រុកទឹកឈូ ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមអំពាវនាវ និងមានក្តីសង្ឃឹមយ៉ាងមុតមាំថា រដ្ឋបាលស្រុក ការិយាល័យ អង្គការសង្គមស៊ីវិល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និង សប្បុរជន មេត្តាជួយគាំទ្រគម្រោងសកម្មភាពឬសេវាជាអាទិភាពនានា ដើម្បីឆ្លើយតបទៅនឹងសំណូមពរ ជាចម្បងៗនៃផែនការអភិវឌ្ឍន៍ស្រុក ។

ថ្ងៃអង្គារ ១៤រោច ខែចេត្រ ឆ្នាំ រោង ឆស័ក ព.ស២៥៦៨
ទឹកឈូ,ថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០២៥
**ជ.ប្រធានក្រុមប្រឹក្សាស្រុក**

# សេចក្តីផ្តើម

ផែនការអភិវឌ្ឍន៍ស្រុករយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) ដែលបានអនុម័ត ដោយក្រុមប្រឹក្សា ស្រុក នាកិច្ចប្រជុំវិសាមញ្ញលើកទី ៤ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០២៥ ។ ក្រុមប្រឹក្សាស្រុកទឹកឈូ គណៈអភិបាល ស្រុក បាននឹងកំពុងអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ដើម្បីអនុវត្តន៍គោលការណ៍ អភិបាលកិច្ចល្អ និងអភិវឌ្ឍន៍ សេដ្ឋកិច្ចមូលដ្ឋាន ស្របតាមច្បាប់គោលនយោបាយវិមជ្ឈការ វិសហ- មជ្ឈការ និង លិខិតបទដ្ឋាន គតិយុត្តិនានាសំដៅលើកកំពស់ចីរភាពដល់ការអភិវឌ្ឍន៍តាមបែបប្រជា- ធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធី វិនិយោគបីឆ្នាំ រំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ២០១០ ស្តីពីការកែសម្រួលមាត្រា ១២ នៃអនុក្រឹត្យស្តីពីការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំ រំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនិងប្រកាសអន្តរក្រសួង លេខ ០៨២ ប្រ.ក របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៧ ស្តីពីការដាក់ឲ្យ ប្រើប្រាស់សេចក្តីណែនាំ បច្ចេកទេស ស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ក្រុមប្រឹក្សាស្រុក អាណត្តិទី ៤ បានរៀបចំផែនការអភិវឌ្ឍន៍ស្រុករយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) ។

ដូចនេះ ដើម្បីឆ្លើយតបទៅនឹងការទទួលខុសត្រូវខ្ពស់របស់ក្រុមប្រឹក្សាស្រុក ជាមួយប្រជាពលរដ្ឋ នៅក្នុងមូល ដ្ឋានឲ្យស្របតាមផែនការអភិវឌ្ឍន៍ស្រុក ដែលបានរៀបចំរួចហើយ ក្រុមប្រឹក្សាស្រុក ចាំបាច់ត្រូវរៀបចំផែនការអ ភិវឌ្ឍន៍ស្រុករយៈពេលប្រាំឆ្នាំដោយមានការចូលរួម និងពិគ្រោះយោបល់យ៉ាងល្អិតល្អន់តាមរយៈការលើកសំណើ គម្រោង តាមបណ្តាឃុំ ការិយាល័យ អង្គការសង្គមស៊ីវិល នានាជុំវិញស្រុក ។ម្យ៉ាងវិញ ទៀតក្រុមប្រឹក្សាស្រុកបាន បញ្ចូល នូវខ្លឹមសារសំខាន់ៗដូចជា៖ ផ្នែក សេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ និង បរិស្ថាន និងការបន្សាំនិងការ ប្រែប្រួលអាកាសធាតុ និង ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សារធារណៈ គម្រោងនៃផែនការអភិវឌ្ឍន៍រយៈ ពេល ប្រាំឆ្នាំ និងក្របខ័ណ្ឌតាមដានវាយតម្លៃ ការអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំស្រុក ។

**ផែនការអភិវឌ្ឍន៍ស្រុករយៈពេលប្រាំឆ្នាំបានប្រព្រឹត្តទៅជាបីជំហានធំៗ ៖**

**ជំហានទី ១ ៖** ការរៀបចំ និងផ្សព្វផ្សាយស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ស្រុក

**ជំហានទី ២ ៖** ការរៀបចំ និងចងក្រងសេចក្តីព្រៀងផែនការអភិវឌ្ឍន៍ស្រុក

**ជំហានទី ៣ ៖** ការពិនិត្យអនុម័តនិងផ្សព្វផ្សាយការអភិវឌ្ឍន៍ស្រុក។

**ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំត្រូវបានចងក្រងជាបួនជំពូកធំៗ ៖**

**ជំពូកទី ១ ៖** ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

**ជំពូកទី ២ ៖** ក្របខណ្ឌអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អណត្តិរបស់ក្រុមប្រឹក្សា

**ជំពូកទី ៣ ៖** កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ

**ជំពូកទី ៤ ៖** ក្របខ័ណ្ឌតាមដាន និងវាយតម្លៃនៃការអនុវឌ្ឍន៍ផែនការអភិវឌ្ឍន៍ស្រុក

# ផែនទី



ផែនទីរដ្ឋបាលស្រុកទឹកឈូ
ជ
មាត្រដ្ឋាន1:90,000
ស្រុកឈូក
ក្រុងបូកគោ
ស្រុកដងទង់
ក្រុងកំពត
សមុទ្រកម្ពុជា
ខេត្តកែប
ផែនទីខេត្តកំពត
កំណត់សំគាល់ :
ព្រំប្រទល់រដ្ឋបាលខេត្ត
ព្រំប្រទល់រដ្ឋបាលក្រុង ស្រុក
ព្រំប្រទល់រដ្ឋបាលឃុំ
សាលាស្រុក
សាលាឃុំ
0 1 2 4 6 8 km
Coordinate System: WGS 1984 UTM Zone 48N
Projection: Transverse Mercator
Datum: WGS 1984

# ជំពូកទី១

## ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

# ជំពូកទី ១៖  ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

## ១.១.  សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច

### ១.១.១ ស្ថានភាពភូមិសាស្ត្រ

ស្រុកទឹកឈូ  ស្ថិតនៅប៉ែកខាងកើតក្រុងកំពត ចំងាយ ០៦ គីឡូម៉ែត  ដែលមានទីតាំងនៅក្នុង ភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ។ មានផ្លូវជាតិ ០២ខ្សែសំខាន់ៗ ឆ្លងកាត់ភូមិសាស្ត្រស្រុក រួមមានផ្លូវជាតិ លេខ ៣ ផ្លូវជាតិលេខ ៣៣ និងមានផ្លូវរថភ្លើង ០១ខ្សែឆ្លងកាត់ពីភ្នំពេញឆ្ពោះទៅកាន់ខេត្ត ព្រះសីហនុ ក្នុងនោះដែរក៏មានប្រកចេញចូលតាមផ្លូវទឹកផងដែរ មានផ្ទៃដីសរុប ១,៣៦១.៧០ គីឡូម៉ែតការេ មានឃុំចំនួន ១៣ឃុំ និងភូមិ ៥៥ មានព្រំប្រទល់រដ្ឋបាលដូចខាងក្រោម៖

- ខាងជើងទល់នឹងស្រុកឈូក  និងស្រុកដងទង់ ខេត្តកំពត
- ខាងត្បូងទល់នឹងខេត្តកែប និងដែនសមុទ្រកម្ពុជា វៀតណាម
- ខាងកើតទល់នឹងស្រុកដងទង់ខេត្តកំពត  និងស្រុកដំណាក់ចង្អើរ ខេត្តកែប
- ខាងលិចទល់នឹងក្រុងកំពត និងក្រុងបូកគោ

បច្ចុប្បន្នមានគ្រួសារសរុបចំនួន ២៣,៣៨៣ គ្រួសារ ប្រជាពលរដ្ឋសរុបចំនួន ១០៨,៣៣៨ នាក់ អាយុ ១៨ឆ្នាំឡើង ៥៥,៨២៧ នាក់ស្រី ៣០,០១១ នាក់ (ទិន្នន័យមន្ទីរផែនការខេត្តឆ្នាំ២០២៤) ។

- ប៉ែកខាងជើងជាតំបន់ព្រៃឈើ  និង  ជួរភ្នំភាគច្រើនជាដីចំការ មានដីស្រែតិចតួចរួមទាំងមានព្រែកស្ទឹងធម្មជាតិជាច្រើន

- ខាងត្បូងឈៀងខាងលិចលាតសន្ធឹងតាមបណ្តោយមាត់សមុទ្រ   មានសក្តានុពល   ក្នុងការផលិតអំបិលនេសាទ និងជាតំបន់ព្រៃកោងកាង

- ដោយឡែកខាងកើតសំបូរដោយជួរភ្នំ ផ្ទៃដីធ្វើស្រែ  ចំការ  ហើយការអភិវឌ្ឍស្រុក ពឹងផ្អែកលើសក្តានុពលធម្មជាតិដែលមានស្រាប់និងការធ្វើកសិកម្មជាចម្បង។

ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិបរិស្ថាននិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ មានដូចខាងក្រោម៖

### ១.១.២ សេចក្តីសង្ខេបព័ត៌មាន និងទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច

**តារាងសង្ខេបទិន្នន័យចម្បងរបស់ស្រុក**

| ល.រ | បរិយាយ | ឆ្នាំ ២០២៤ |
|---|---|---|
| **ព័ត៌មានទូទៅ** | | |
| ១ | ផ្ទៃដី | 1.361,70 |
| ២ | ចំនួនឃុំ | 13 |
| ៣ | ចំនួនភូមិ | 55 |
| ៤ | ចំនួនគ្រួសារ | 23,383 |
| ៥ | % មេគ្រួសារជាស្ត្រី | 14.6 |
| ៦ | ចំនួនប្រជាជនសរុប | 108,338 |
| ៧ | ចំនួនស្រី | 52,511 |

| ល.រ | បរិយាយ | ឆ្នាំ ២០២៤ |
|---|---|---|
| ៨ | ចំនួនប្រុស | 55,8727 |
| ៩ | % អ្នកកមានអាយុពី ០-១៧ឆ្នាំ | 35.9 |
| ១០ | % អ្នកកមានអាយុពី ១៨-៦០ឆ្នាំ | 53.6 |
| ១១ | % អ្នកកមានអាយុពី ៦០ឆ្នាំឡើង | 10.5 |
| ១២ | កំណើនប្រជាជនប្រចាំឆ្នាំ (%) | 2.5 |
| ១៣ | អត្រាភាពក្រីក្រ (%) | ១៨.២២ |
| ១៤ | % អ្នកកមានមុខរបរចម្បងផ្នែកកសិកម្ម | 67,9 |
| ១៥ | % អ្នកកមានមុខរបរចម្បងផ្នែកសិប្បកម្ម | 0.6 |
| ១៦ | % អ្នកកមានមុខរបរចម្បងផ្នែកសេវាកម្ម | 31.5 |
| ១៧ | %មនុស្សទៅរកការងារធ្វើនៅក្នុងប្រទេស | 66.5 |
| ១៨ | %មនុស្សទៅរកការងារធ្វើនៅក្រៅប្រទេស | 52.1 |
| ១៩ | % ខ្នងផ្ទះមានអគ្គិសនីប្រើប្រាស់ | 93.8 |
| **អប់រំ** | | |
| ២០ | % កុមារអាយុ ៣-៥ឆ្នាំបានចូលរៀន | 36.1 |
| ២១ | % កុមារអាយុ ៦ឆ្នាំបានចូលរៀន | 88.2 |
| ២២ | % កុមារអាយុ ៦-១១ឆ្នាំបានចូលរៀន | 80.6 |
| ២៣ | % កុមារអាយុ ១២-១៤ឆ្នាំនៅរៀន | 87.9 |
| ២៤ | % អ្នកចេះអក្សរអាយុ ១៥-១៧ឆ្នាំ | 99.3 |
| ២៥ | % អ្នកចេះអក្សរអាយុ ១៨-៤៥ឆ្នាំ | 97.5 |
| **សុខភាព** | | |
| ២៦ | ចំនួនមណ្ឌលសុខភាព | 9 |
| ២៧ | % ស្ត្រីសម្រាលកូនដោយឆ្មបពេទ្យ | 100.0 |
| ២៨ | អត្រាស្លាប់របស់មាតាក្រោលពេលសម្រាល (០-១ខែ) ក្នុង១ពាន់កំណើត | 0 |
| ២៩ | អត្រាស្លាប់របស់ទារកក្រោលពេលកើត (០-១ខែ) ក្នុង ១ពាន់កំណើត | 0 |
| ៣០ | % កុមារអាយុពី៩-១២ខែ បានចាក់ថ្នាំបង្ការគ្រប់ចំនួន | 99.2 |
| ៣១ | ចំនួនគ្រួសារមានសមាជិកកើតជំងឺអេដស៍ | 90 |
| **ងាយរងគ្រោះ** | | |
| ៣២ | ចំនួនជនពិការ | 1.022 |
| ៣៣ | %ជនពិការអាយុ១៨ឆ្នាំឡើងមិនអាចរកចំណូលបាន | 29.0 |
| ៣៤ | ចំនួនកុមារកំព្រាឪពុកម្តាយស្លាប់ដោយជំងឺអេដស៍ | 28 |
| ៣៥ | ចំនួនចាស់ជរាគ្មានទីពឹង(អាយុ៦១ឆ្នាំឡើង) | 72 |
| **ធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ** | | |
| ៣៦ | ចំនួនគ្រួសាររងគ្រោះដោយខ្យល់កន្ត្រាក់ | 767 |

| ល.រ | បរិយាយ | ឆ្នាំ ២០២៤ |
|---|---|---|
| ៣៧ | ចំនួនគ្រួសាររងគ្រោះដោយទឹកជំនន់ | 2 |
| ៣៨ | ចំនួនគ្រួសាររងគ្រោះដោយរាំងស្ងួត | 0 |
| ៣៩ | % គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | 3.0 |
| ៤០ | % គ្រួសារមានទឹកស្អាតប្រើប្រាស់ | 69.3 |
| ក្នុងនោះ: | គ្រួសារមានទឹកអណ្តូងស្នប់ឬអណ្តូងចំរុះ | 2,990 |
| | គ្រួសារមានទឹកអណ្តូងជីកមានការការពារ | 1,055 |
| | គ្រួសារមានទឹកភ្លៀងមានការការពារ | 631 |
| | % គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | 83.8 |
| ៤១ | % គ្រួសារមានទឹកអណ្តូងជីកមិនមានការការពារ | 6.4 |
| **រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | |
| ៤២ | % កុមារបានចុះសំបុត្រកំណើត(០-៣០ថ្ងៃ) | 89.3 |
| ៤៣ | ចំនួនគ្រួសារមានអំពើហឹង្សាក្នុងគ្រួសារ | 33 |
| ៤៤ | ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរ | 9 |
| ៤៥ | ចំនួនអ្នកស្លាប់ដោយអំពើហឹង្សានានា | 1 |
| ៤៦ | ចំនួនគ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀន | 60 |

## ១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

ស្រុកទឹកឈូ ស្ថិតនៅប៉ែកខាងកើតទីរួមខេត្តកំពតចំងាយ ០៦ គីឡូម៉ែត្រ ដែលមានទីតាំងនៅក្នុងភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ។មានផ្លូវជាតិ ០២ខ្សែសំខាន់ៗ ឆ្លងកាត់ភូមិសាស្ត្រស្រុក រួមមានផ្លូវជាតិលេខ ៣ ផ្លូវជាតិលេខ ៣៣ និងមានផ្លូវរថភ្លើង ១ខ្សែឆ្លងកាត់ពីភ្នំពេញឆ្ពោះទៅកាន់ខេត្តព្រះសីហនុ ក្នុងនោះដែរក៏មានច្រកចេញចូលតាមផ្លូវទឹកផងដែរ មានផ្ទៃដីសរុប ១៣៦១.៧០ គីឡូម៉ែត្រការេ មានឃុំចំនួន ១៣ឃុំ និងភូមិ ៥៥ មានព្រំប្រទល់រដ្ឋបាលដូចខាងក្រោម៖

- ខាងជើងទល់នឹងស្រុកឈូក និងស្រុកដងទង់ ខេត្តកំពត
- ខាងត្បូងទល់នឹងខេត្តកែប និងដែនសមុទ្រកម្ពុជា វៀតណាម
- ខាងកើតទល់នឹងស្រុកដងទង់ខេត្តកំពត និងស្រុកដំណាក់ចង្អើរ ខេត្តកែប
- ខាងលិចទល់នឹងក្រុងកំពត និងក្រុងបូកគោ

បច្ចុប្បន្នមានគ្រួសារសរុបចំនួន ២៣,៣៨៣ គ្រួសារ ប្រជាពលរដ្ឋសរុបចំនួន ១០៨,៣៣៨ នាក់ អាយុ ១៨ឆ្នាំឡើង ៥៥,៨២៧ នាក់ស្រី ៣០,០១១ នាក់ (ទិន្នន័យមន្ទីរផែនការខេត្តឆ្នាំ២០២៤) ។

- ប៉ែកខាងជើងជាតំបន់ព្រៃឈើ និង ជួរភ្នំភាគច្រើនជាដីចំការ មានដីស្រែតិចតួចរួមទាំងមានព្រែកស្ទឹងធម្មជាតិជាច្រើន
- ខាងត្បូងឈៀងខាងលិចលាតសន្ធឹងតាមបណ្តោយមាត់សមុទ្រ មានសក្តានុពល ក្នុងការផលិតអំបិល នេសាទ និងជាតំបន់ព្រៃកោងកាង
- ដោយឡែកខាងកើតសំបូរដោយជួរភ្នំ ផ្ទៃដីធ្វើស្រែ ចំការ ហើយការអភិវឌ្ឍស្រុក ពឹងផ្អែកលើសក្តានុពលធម្មជាតិដែលមានស្រាប់និងការធ្វើកសិកម្មជាចម្បង។

ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិបរិស្ថាននិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ មានដូចខាងក្រោម៖

### ១.២.១. ស្ថានភាពសេដ្ឋកិច្ច

ភាពរីកចំរើននៃសេដ្ឋកិច្ចរបស់ស្រុក ពឹងផ្អែកលើវិស័យនានា ដែលមានក្នុងភូមិសាស្ត្រ ។ សក្តានុពលនៃការអភិវឌ្ឍលើវិស័យទាំងអស់នោះ ជាចលករជម្រុញនូវភាពរីកចំរើន និងកាត់បន្ថយ ភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងស្រុកទឹកឈូ ។ វិស័យសំខាន់ៗរួមមាន អាជីវកម្ម កសិកម្ម ឧស្សាហកម្ម គមនាគមន៍ សេវាកម្ម ការវិនិយោគ ការទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ ។ល។

#### ១.២.១.១ អាជីវកម្ម

**ក-** ប្រភេទមុខរបរជំនួញ ក្រៅពីវិស័យកសិកម្មប្រជាពលរដ្ឋក្នុងស្រុកទឹកឈូនៅមានប្រកបរបរលក់ដូរចិញ្ចឹមជីវិត និងជួយដល់ការរីកចំរើនសេដ្ឋកិច្ចក្នុងស្រុក ។ មុខរបរក្នុងវិស័យពាណិជ្ជកម្មរួមមាន៖

- ការទិញលក់ស្រូវ ពោត សណ្តែក គ្រាប់ស្វាយចន្ទី បន្លែ ផ្លែឈើគ្រប់ប្រភេទ
- ការទិញលក់ភោគផលនេសាទសមុទ្រ
- ដេប៉ូលក់គ្រឿងសំណង់
- ស្ថានីយ៍លក់ប្រេងឥន្ទនៈ
- លក់គ្រឿងឧបភោគបរិភោគ

- ផលិតផលកែច្នៃផ្សេងៗ។

ខ-ប្រភេទសិប្បកម្ម មានដូចជា សិប្បកម្មផលិតទឹកត្រី ទឹកកក ទឹកបរិសុទ្ធ ។ បច្ចុប្បន្នសិប្បកម្មទាំងនោះ កំពុងដំណើរការ និង ខិតខំកែប្រែ គុណភាពជាប្រចាំ ដើម្បីឆ្លើយតបសេចក្ដីត្រូវការរបស់អតិថិជន និងឆ្ពោះទៅរកការប្រកួតប្រជែងលើ ទីផ្សារ ។

គ-ជាងជួសជុលមានម៉ូតូ រថយន្ត ទូរទស្សន៍ និង ជួសជុលទូរសព្ទ ។ ល ។ ដើម្បីបម្រើសេចក្ដីត្រូវការរបស់អ្នកប្រើប្រាស់ប្រចាំថ្ងៃ និងនៅគ្រប់ទីកន្លែង។ ពីមួយថ្ងៃទៅមួយថ្ងៃពួកគាត់កំពុង អភិវឌ្ឍតាមបច្ចេកវិជ្ជាដើម្បីឆ្លើយតបដល់អ្នកប្រើប្រាស់ និងពង្រឹងមុខរបរឲ្យកាន់តែប្រសើរឡើង ។ ទន្ទឹមនឹងការរីកចម្រើន ស្រុកក៏ជួបបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- គុណភាពផលិតមិនទាន់ឆ្លើយតបការប្រកួតប្រជែង និងទំនិញមកពីក្រៅ
- អាជីវកម្មមានលក្ខណៈតូចតាចនិងនៅរាយប៉ាយមិនទាន់មានការគ្រប់គ្រងច្បាស់លាស់
- កន្លែងអាជីវកម្ម-សិប្បកម្មមួយចំនួនមិនទាន់មានច្បាប់អនុញ្ញាត
- អាជីវករមួយចំនួនមិនបានគោរពច្បាប់ និងបង់ពន្ធជូនរដ្ឋ
- ជំនាញជាងជួសជុលខ្លះមិនបានឆ្លងកាត់ការបណ្ដុះបណ្ដាល

### ១.២.១.២ កសិកម្ម

វិស័យកសិកម្ម ជាមុខព្រួញស្នូលសំរាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និង វិស័យនានាឱ្យរីកចំរើន។ តាមសៀវភៅទិន្នន័យស្រុកឆ្នាំ២០២៤ បញ្ជាក់ឲ្យឃើញថាគ្រួសារមានរបរកសិកម្ម ជាចម្បង មាន ៦៧.៩% ស្មើនឹងចំនួនមនុស្សសរុប៣២,១១៣នាក់ ក្នុងនោះគ្រួសារមានមុខរបរធ្វើស្រែជាចម្បងមាន ៤៥.២% ស្មើនឹងចំនួនមនុស្ស ២៤,១៣៩ នាក់ និងមានមុខរបរដាំបន្លែរយៈពេលវែង ១០.៧% រយៈ ពេលខ្លី ៤.០% ដំណាំបន្លែ ២.៩% នេសាទ ២.០% ចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ២.៩% អនុផលព្រៃឈើ ០.៣% ។ ក្នុងពេលបច្ចុប្បន្នស្រុកមានផ្ទៃដីបង្កបង្កើនផលសរុប ១៣,៧២៩ ហិចតា ក្នុងនោះផ្ទៃដីស្រូវវស្សាសរុបប្រមាណ ១៣,៩៩០ ហិចតា និងដីចំការចំនួន ៥,៨៤៨.៨៥ហិចតា ។ មធ្យោបាយសំខាន់ៗដែលប្រើក្នុងវិស័យកសិកម្មនៅស្រុកទឹកឈូមានត្រាក់ទ័រមានចំនួន ៨៦ គ្រឿង គោយន្តមាន ២,៦៦១ គ្រឿង គោចំនួន ១៧.៤៧៧ក្បាល ក្របី ៦៦ក្បាល ជ្រូកចំនួន ៩,៧០៤ក្បាល មាន់សរុប ១៦២,៨៣៦ ក្បាល ទាសរុប ២៩,៧៨១ក្បាល ពពែ ១៤៨ក្បាល និងក្ងាន ៦៤ក្បាល ។

**កំណើននេះអាចវាយតម្លៃតាមសក្ដានុពលសំខាន់ៗរួមមាន៖**

- ភូមិសាស្ត្រមានលក្ខណៈអំណោយផលដល់ការដាំដុះដំណាំស្រូវ ដំណាំកសិឧស្សាហកម្មម្រេច កៅស៊ូ ដូង ស្វាយ ស្វាយចន្ទី ទុរេន ដំណាំរួមផ្សំផ្សេងៗ និងការចិញ្ចឹមសត្វដែលអាចទាញយកទឹកប្រើពីប្រភពដ៏សំខាន់ គឺអាងស្តុកទឹកប្រទាក់ក្រឡាស្ថិតក្នុងឃុំកូនសត្វ ។

-បន្លែជាដំណាំដែលប្រជាកសិករស្ទើរគ្រប់គ្រួសារ អាចអនុវត្តន៏បានក្នុងស្រុកសម្រាប់បំរើសេចក្ដីត្រូវការក្នុងស្រុក តំបន់ និង នាំចេញទៅប្រទេសជិតខាង។

- មានដំណាំឈើហូបផ្លែជាច្រើនមុខដូចជាទុរេន ស្វាយ ដូង ទៀប មង្ឃុត ក្រូច សាម៉ាវ ចេក ដែលអាចផ្គត់ផ្គង់ក្នុងស្រុក និង នាំទៅលក់ក្រៅស្រុកបាន ។

-ភូមិសាស្ត្រនេះ ក៏បានអនុគ្រោះផងដែរដល់ដំណាំកសិឧស្សាហកម្មរយៈពេលខ្លី ដូចជាអំពៅ និងសណ្ដែកដីជាដើម ។

-ក្រៅពីនេះការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ក៏មានការចិញ្ចឹមជាលក្ខណៈកសិដ្ឋាន ដូចជាគោ ក្របី ជ្រូក មាន់ ទា និងពពែ។ មិនតែប៉ុណ្ណោះការនេសាទសមុទ្រក៏ជាប្រភព ចំណូលដ៏ សំខាន់នៃគ្រួសារប្រជាពលរដ្ឋក្នុង ស្រុកទឹកឈូផងដែរ ។

**ទន្ទឹមនឹងសក្តានុពលខាងលើ ស្រុកក៏នៅជួបបញ្ហាប្រឈមមួយចំនួនក្នុងវិស័យនេះដូចជា៖**

- ប្រព័ន្ធធារាសាស្ត្រសំរាប់ស្រោចស្រប់ពុំទាន់ឆ្លើយតបតម្រូវការ
- កសិករនៅប្រើទម្លាប់ធម្មជាតិ( ការដាំដុះ និងការចិញ្ចឹមសត្វ....)
- ការទទួលយកបច្ចេកទេសនៅមានកម្រិត/មធ្យោបាយផលិតមិនទាន់ទំនើប
- ជួបប្រទះការបំផ្លាញពីសត្វល្អិត និងគ្រោះធម្មជាតិនានា
- ការស្រាវជ្រាវ និងការប្រើប្រាស់ពូជល្អៗនៅមានកំរិត
- ផ្ទៃដីដាំដំណាំរបស់គ្រួសារកសិករមួយចំនួនមានទំហំតូច
- ការចំលងជម្ងឺទៅសត្វពាហនៈបន្តកើតមានតិចតួច
- ការគ្រប់គ្រងនៃការប្រើប្រាស់ជីគីមីនិងថ្នាំពុលកសិកម្មនៅតែមានការបង្កគ្រោះថ្នាក់ដល់កសិករ ។
- ទីផ្សារមិនទាន់ឆ្លើយតបការផលិត
- អត្រាបសុបក្សីឈឺ និងងាប់នៅមានបន្តិចបន្តួចជាប្រចាំ ។

### ១.២.១.៣ ឧស្សាហកម្ម និងសិប្បកម្ម

**ក. សិប្បកម្ម និង រោងចក្រ ៖** ស្រុកមានរោងចក្រសិប្បកម្ម ចំនួន ៩៤ ទីតាំងកំពុងដំណើរការក្នុងពេលបច្ចុប្បន្នដូចជា៖

- ឡផលិតទឹកត្រី ០២ ទីតាំង
- ឧស្សាហកម្មផលិតទឹកកក ០២ ទីតាំង
- ផលិតទឹកបរិសុទ្ធ(ដប) ១១ ទីតាំង
- ផលិតសំបកទឹកសុទ្ធ ០២ ទីតាំង
- ទឹកស្អាត(ឯកជន) ០៣ ទីតាំង
- ផលិតទឹកជ្រលក់ ០១ ទីតាំង
- សិប្បកម្មផលិតឥដ្ឋ ០៣ ទីតាំង
- សិប្បកម្មផលិតចង្ក្រានដី ០២ ទីតាំង
- រងាស់អំបិល ០១ ទីតាំង
- រោងម៉ាស៊ីនកិនស្រូវ ៣០ ទីតាំង
- រោងម៉ាស៊ីនម្សៅអង្ករ ០៨ ទីតាំង
- ឡផលិតនំប៉ុង ០២ ទីតាំង
- សិប្បកម្មកាត់ស័ង្កសី ០៣ ទីតាំង
- ផ្សារដែក ២០ ទីតាំង
- រោងចក្រស៊ីម៉ងត៍ ០១ ទីតាំង
- ចំរាញ់ប្រេងចាន់ ០១ ទីតាំង

- ផលិតនំផ្សេងៗ ០១ ទីតាំង
- ផលិតតៅហ៊ូរ ០១ ទីតាំង

**ខ.ការងារផលិតអំបិល៖**ស្រុកមានផ្ទៃដីផលិតអំបិលសរុប ចំនួន ១,៣៨៦.៩៩ ហិចតា ចែកជា ១ មណ្ឌល ស្ថិតក្នុងឃុំជុំគ្រៀល និងមានក្រុមអ្នកផលិតអំបិលចំនួន ៤៥ ក្រុម ។

ជាប្រចាំស្រុកបានសហការជាមួយអ្នកពាក់ព័ន្ធជម្រុញដល់សហគមន៍ផលិតអំបិលសំដៅកែលំអគុណភាព និងធានាបាននូវការផ្គត់ផ្គង់លើទីផ្សារ ។

**គ.ការងារមាត្រាសាស្រ្ត៖**ដើម្បីធានាដល់ការធ្វើពាណិជ្ជកម្មប្រកបដោយយុត្តិធម៌និងមាន ភាពត្រឹមត្រូវការប្រើប្រាស់ឧបករណ៏មាត្រាសាស្រ្ត ជាជំហានដ៏ត្រឹមត្រូវបំផុតឆ្ពោះទៅរកទំនុកចិត្តរវាង អ្នកផ្គត់ផ្គង់ និង អ្នកប្រើប្រាស់ និងការប្រកួតប្រជែងដោយត្រឹមត្រូវ ជាប្រចាំមន្ត្រីជំនាញបានធ្វើការ ផ្សព្វផ្សាយ និង ត្រួតពិនិត្យដោយឧបករណ៏ដល់គ្រប់សិប្បកម្ម កន្លែងផលិត និងអ្នកពាក់ព័ន្ធ ។ ក្នុងនោះដែរស្រុកទឹកឈូមាន បញ្ចូល និងលក់ហ្គាសមាន ៣៥ ទីតាំង ស្ថានីយ៏ប្រេងឥន្ធនៈ៣៧ កន្លែង។ បញ្ហាប្រឈមដែលស្រុកជួបប្រទះមាន៖

- ការផ្សព្វផ្សាយច្បាប់មិនទាន់បានទូលាយដល់មូលដ្ឋាន
- ម្ចាស់សិប្បកម្មមួយចំនួនមិនទាន់បានអនុវត្តន៏តាមច្បាប់
- ការផលិតមិនទាន់បានតាមស្តង់ដារ
- ខ្វះទុនបង្កើនគុណភាពអំបិល និងការនាំចេញ
- ខ្វះឧបករណ៍ និងការយល់ដឹងពីមាត្រាសាស្រ្តមានកម្រិត។

**១.២.១.៥ គមនាគមន៏:**

ស្រុកទឹកឈូ មានលក្ខណៈអំណោយផលពីការធ្វើដំណើរតាមផ្លូវគមនាគមន៏គ្រប់ប្រភេទដូចជា មានផ្លូវជាតិពីរខ្សែឆ្លងកាត់គឺផ្លូវលេខ ០៣ លេខ ៣៣ និង ផ្លូវរវាងក្រុងចំនួន ០១ ខ្សែ ផ្លូវរថភ្លើង ០១ខ្សែ ឆ្លងកាត់ពីភ្នំពេញឆ្ពោះទៅខេត្តព្រះសីហនុ ។ដោយឡែកសំរាប់ការប្រើប្រាស់ថវិកាអភិវឌ្ឍន៏ស្រុកឆ្នាំ២០២៤ បានជួសជុលផ្លូវបេតុងអាមេចំនួន ០៣ ខ្សែ ប្រវែង ៦៤០ ម៉ែត្រ ។នៅតាមបណ្តាឃុំផ្លូវក៏បានសាងសង់រួចនិងកំពុងបន្តសាងសង់ជារៀងរាល់ឆ្នាំបន្ថែមទៀតផ្លូវដែលបានសាងសង់នាពេលកន្លងមកមានផ្លូវបេតុងចំនួន១៣ខ្សែ ប្រវែង ៧,៣៨២ ម៉ែត្រ ផ្លូវលំគ្រួសក្រហមចំនួន ០១ខ្សែ ប្រវែង ៥,៤៨៥ ម៉ែត្រ និងសំណង់លូ ចំនួន ៥០០ ម៉ែត្រ (តួលេខឆ្នាំ២០២៤)។ក្រៅពីនោះផ្លូវទឹកចេញចូលតាមច្រកសមុទ្រដែលផ្តល់ភាពងាយស្រួលដល់ការធ្វើដំណើរនិងបណ្តូលពាណិជ្ជកម្មគ្រប់ប្រភេទឆ្ពោះទៅកាន់ទីផ្សារនិងបម្រើឲ្យវិស័យទេសចរណ៍ ។

**ទន្ទឹមនឹងភាពងាយស្រួលខាងលើ ស្រុកនៅជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចជា៖**

- ផ្លូវមួយចំនួនទ្រុឌទ្រោមមិនទាន់មានការជួសជុលឡើងវិញ
- ផ្លូវមួយចំនួនមិនទាន់បានកែលំអពីផ្លូវគ្រួស.ដី អោយទៅជាផ្លូវកៅស៊ូ ឫបេតុង
- ផ្លូវធ្វើដំណើរតាមតំបន់ខ្លះ មិនទាន់ឆ្លើយតបតម្រូវការប្រជាពលរដ្ឋ
- ករណីគ្រោះថ្នាក់ចរាចរនៅតែកើតមាន
- ការអនុវត្តន៏ច្បាប់នៅមានកម្រិត
- ប្រជាពលរដ្ឋមួយចំនួនមិនយល់ពីច្បាប់ចរាចរផ្លូវគោក

**១.២.១.៦. សេវាកម្ម**

ក- ទឹកស្អាត៖ ប្រជាពលរដ្ឋដែលបានប្រើប្រាស់ទឹកស្អាតមានចំនួន ១៦,២០៥ គ្រួសារ ស្មើនឹង ៦៩.៣%

នៃគ្រួសារសរុប។ ស្ថានីយ៍ទឹកស្អាតនៅក្នុងទីតាំងស្រុកទឹកឈូ មានចំនួន ០២ មូលដ្ឋាន ក្នុងនោះស្ថិតក្នុងឃុំកូនសត្វ និងឃុំម៉ាក់ប្រាង្គ ។ ដែលចំនួននេះមិនទាន់បានឆ្លើយតបសេចក្តីត្រូវការ ចំពោះប្រជាពលរដ្ឋនៅឡើយ ។

ខ-ទេសចរណ៍៖ ស្រុកមានទីតាំងភូមិសាស្ត្រអំណោយផលដល់វិស័យទេសចរណ៍មាន ១០កន្លែងជាលក្ខណៈធម្មជាតិមាន០៣កន្លែង(រមណីយដ្ឋានទឹកឈូ កោះតាជា និង ទំនប់ប្រទាក់ក្រឡា)និង ទេសចរណ៍វប្បធម៌ចំនួន ០២កន្លែង (រមណីយដ្ឋានភ្នំឈ្ងោកនិង ភ្នំសេដាអោន) ។និងមានតំបន់ឆ្នេរព្រែកកោះស្មៅ សហគមន៍ត្រពាំងសង្កែ សហគមន៍កំពង់សាមគ្គី ដូងទេរ ឧទ្យានដងព្រែក និងតំបន់ទេសចរផ្សេងៗទៀត បច្ចុប្បន្នបាននឹងកំពុងដំណើរការទទួលភ្ញៀវជាតិ និង អន្តរជាតិជាប្រចាំ ។

**ទន្ទឹមនឹងលក្ខណៈអំណោយផលខាងលើក៏នៅមានបញ្ហាប្រឈមមួយចំនួនដូចជា៖**

- ការផ្តល់សេវាទឹកស្អាតមិនទាន់ឆ្លើយតបតម្រូវការប្រជាពលរដ្ឋ
- ទឹកស្អាតមានតម្លៃខ្ពស់
- ម្ចាស់មូលដ្ឋានផលិតទឹកស្អាតមួយចំនួនមិនបានសុំច្បាប់អនុញ្ញាតពីមន្ទីរ
- រមណីយដ្ឋានមួយចំនួន មិនទាន់បានកែលម្អ

រមណីយដ្ឋានទេចរណ៍ស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរទេសចរណ៍ខេត្ត ។

**១.២.១.៧.ការវិនិយោគ**

ដោយស្ថានភាពភូមិសាស្ត្ររបស់ស្រុក អំណោយផលពី ធម្មជាតិសម្រាប់វិស័យនានាដែលបង្កការងាយស្រួលដល់អ្នកវិនិយោគក្នុង និង ក្រៅស្រុកមកបណ្តាក់ទុនវិនិយោគ ទាំងផ្នែកកសិកម្ម និងឧស្សាហកម្ម ។ រោងចក្រឧស្សាហកម្មទាំងនោះមានដូចជា៖

- រោងចក្រស៊ីម៉ង់ត៍ចក្រីទីង
- រ៉ារីអគ្គិសនីស៊ីណូហាយជ្រូកំចាយ
- រោងចក្រដេរកូនបាល់(ក្រុមហ៊ុនដាប៉ុនស្ល៉ត ឯ.ក)

**ទន្ទឹមនិងការរីកចម្រើនខាងលើ ស្រុកនៅមានជួបបញ្ហាប្រឈមដូចជា៖**

- រោងចក្រ ឧស្សាហកម្មដែលបានធ្វើការវិនិយោគលើទីតាំងភូមិសាស្ត្ររបស់ស្រុក តែស្ថិតក្រោមការគ្រប់គ្រងរបស់ខេត្តនិងក្រសួងជំនាញ ។
- ពិបាកក្នុងការទំនាក់ទំនង និងសុំកិច្ចសហការផ្តល់ព័ត៌មានពីអ្នកវិនិយោគ ។

**១.២.១.៨. ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ**

ដោយឡែករដ្ឋបាលស្រុកទឹកឈូ មានការចងសម្ព័ន្ធភាព និងការទំនាក់ទំនង កិច្ចសហ-ប្រតិបត្តិការជាមួយបណ្តាប្រទេសជិតខាង ។

**១.២.១.៩. ធនធានទឹក**

ធារាសាស្ត្រជាវិស័យដ៏សំខាន់មួយដែលគាំទ្រដល់វិស័យកសិកម្ម ឧស្សាហកម្ម និង វិស័យផ្សេងៗជាច្រើនទៀតសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ស្រុកទឹកឈូ។ ក្នុងនោះមានប្រឡាយស្រោច ស្រព ប្រឡាយមេស្ទឹងកែវឆ្លងកាត់ ១១ឃុំ អាងស្តុកទឹកចំនួន ០១កន្លែង (ទំនប់ប្រទាក់ក្រឡា នៅឃុំ កូនសត្វ) ស្ថានីយបូមទឹក ប្រឡាយ និង មានស្ទឹងធម្មជាតិ ដែលផ្តល់លទ្ធភាពដល់ការផ្គត់ផ្គង់លើការស្រោចស្រពស្រូវរដូវប្រាំង និងវស្សា ព្រមទាំង ដំណាំកសិកម្មផ្សេងៗទៀត។ មិនតែប៉ុណ្ណោះក៏មាន ប្រភពទឹក ស្ទឹង បឹង អូរ ធម្មជាតិផងដែរ ក្នុងការបម្រើសេចក្តីត្រូវការជូនប្រជាពលរដ្ឋក្នុងស្រុកទឹកឈូ ។

**ទន្ទឹមនឹងសក្តានុពលស្រុកកំពុងបានជួបប្រទះនូវបញ្ហាប្រឈម មួយចំនួនដូចជា៖**

- ប្រពន្ធ័ស្រោចស្រពមិនទាន់ឆ្លើយតបតាមតម្រូវការ
- ការចែកចាយទឹកនៅរដូវប្រាំង មានកម្រិត
- ស្ទឹង-អូរធម្មជាតិមួយចំនួនគ្មានទឹកហូរនៅរដូវប្រាំង
- ខ្វះការចូលរួមថែរក្សាពីប្រជាកសិករ

**១.២.១.១០. ជលផលៈ**

ឃុំមួយចំនួននៃស្រុកទឹកឈូ លាតសន្ធឹងជាប់មាត់សមុទ្រ ដែលអំណោយផលដល់ការនេសាទ ជាលក្ខណៈគ្រួសារ និង ឧស្សាហកម្ម ។ មិនតែប៉ុណ្ណោះក៏នៅមានវាលស្រែ ត្រពាំង ស្ទឹង បឹង អូរធម្មជាតិ ជាច្រើនកន្លែង ដែលអំណោយផលដល់ការនេសាទ ជាប្រភពសេដ្ឋកិច្ចដ៏សំខាន់ ។ ក្រៅពីចំណុច ខាងលើប្រជាកសិករបានចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ តាមស្រះធម្មជាតិដើម្បីរួមចំណែកដល់កំណើនសេដ្ឋកិច្ច ។ មិនតែប៉ុណ្ណោះស្រុក បានសហការជាមួយផ្នែកឯកជន និង ដៃគូអភិវឌ្ឍន៍នានាអភិរក្ស និងដាំកូនកោងកាងឡើងវិញក្នុងន័យ ធានាដល់កំណើនផលនេសាទ ។

**ទន្ទឹមនឹងនេះក៏មានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖**

- នៅមានការកាប់បំផ្លាញព្រៃលិចទឹកដែលជាជម្រកមច្ឆាជាតិ
- នៅមានការប្រើឧបករណ៍នេសាទខុសច្បាប់
- នៅមានបទល្មើសចាប់កូនក្តាមតូចៗ
- មានការប្រើជាតិគីមីពុលនៅតាមវាលស្រែ
- ការយល់ដឹងពីច្បាប់ជលផលនៅមានកម្រិត
- ការអនុវត្តន៏ច្បាប់នៅមានកម្រិត
- ប្រជាពលរដ្ឋមិនយល់ពីច្បាប់ចរាចរណ៍ផ្លូវគោក

**១.២.១.១១.ការងារធនធានរ៉ែ និងថាមពល**

ក- ធនធានរ៉ែ៖ ស្រុកទឹកឈូក៏មានប្រភពចំណូលពីធនធានរ៉ែផងដែរក្នុងនោះមាន៖

| | |
|---|---|
| - អាជ្ញាប័ណ្ណថ្មសំណង់ | ០១ មូលដ្ឋាន |
| - អាជ្ញាប័ណ្ណស៊ីម៉ង់ត៍កម្ពុជាចក្រីទីង | ០១ មូលដ្ឋាន |
| - អាជ្ញាប័ណ្ណខ្សាច់ទឹកសាប | ០១ មូលដ្ឋាន |
| - អាជ្ញាប័ណ្ណដីក្រហម | ០២ មូលដ្ឋាន |
| - អាជីវកម្មកាយដីចល័ត | ០៨ អាជ្ញាប័ណ្ណ |

ខ- អគ្គិសនី៖ ជាប្រភពថាមពលដ៏សំខាន់ដែលជួយដល់វិស័យនានា ពិសេសឧស្សាហកម្ម។ ស្រុកបានទំនាក់ទំនងជាមួយដៃគូពាក់ព័ន្ធក្នុងការពង្រីកវិស័យថាមពលនេះនាពេលខាងមុខ ព្រោះថាក្នុងពេលបច្ចុប្បន្ន ប្រជាពលរដ្ឋក្នុងស្រុកទឹកឈូ ប្រើប្រាស់ភ្លើងអគ្គិសនីប្រមាណ ១៩,៦៧១ ខ្នងផ្ទះ។

**បញ្ហាប្រឈមដែលស្រុកជួបប្រទះរួមមាន៖**

- ការអនុវត្តន៏ច្បាប់នៅមានកំរិត
- ការតបណ្តាញអគ្គីសនី មិនទាន់ឆ្លើយតបនិងតម្រូវការប្រជាពលរដ្ឋ

### ១.២.២. ស្ថានភាពផ្នែកសង្គមកិច្ច

### ១.២.២.១. ស្ថានភាពអប់រំ

ដើម្បីរួមចំណែកសម្រេចគោលនយោបាយទាំងបី នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ការិយាល័យអប់រំ យុវជន និងកីឡាស្រុកទឹកឈូ បានខិតខំរិះរកគ្រប់មធ្យោបាយដើម្បីប្រមូលសិស្សក្នុងវ័យសិក្សា និងយុវជនក្រៅសាលាឲ្យបានចូលរៀនគ្រប់ៗគ្នា និង ជំរុញសាលាទាំងអស់ក្នុងស្រុកអោយទទួលបានស្តង់ដារសាលារៀនគំរូ។ នៅក្នុងឆ្នាំសិក្សា ២០២៣-២០២៤ នេះទូទាំងស្រុកមានសាលាមត្តេយ្យធនធានចំនួន ០១ កន្លែង០៣ថ្នាក់ មត្តេត្យរដ្ឋ ១៥ កន្លែង មត្តេយ្យសិក្សាសហគមន៍ ២៣ កន្លែងមត្តេយ្យឯកជន ០១ កន្លែង សាលាបឋមសិក្សា ៤៥ អនុវិទ្យាល័យ ១១ កន្លែង វិទ្យាល័យ ០៣ កន្លែង និងវិទ្យាល័យឯកជនចំនួន ០៣ កន្លែង មានបុគ្គលិកសិក្សាសរុប ៥៨ នាក់ ស្រី ១១នាក់ ។ សិស្សសរុប ១៩,១៨៣ នាក់ ក្នុងនោះសិស្សស្រី ៩,៥៨៦នាក់ (តួលេខនេះ មិនរាប់បុគ្គលិក និងសិស្សនៅសាលា ឯកជនទេ ) ។

តាមទិន្នន័យដែលការិយាល័យអប់រំ យុវជន និងកីឡាស្រុកទឹកឈូ ប្រមូលបានពីសាលា បានបង្ហាញថា៖

- កុមារអាយុពី ០៦ ដល់ ១១ឆ្នាំ ចូលរៀន មានចំនួន ១០,៩៨៣ នាក់ ស្មើនឹង ៨០.៦%
- យុវជនអាយុពី ១២ ដល់ ១៤ឆ្នាំ ចេះអក្សរមានចំនួន ២,៥៥៨ នាក់ ស្មើនឹង ៨៨%
- យុវជនអាយុពី ១៥ ដល់ ១៧ឆ្នាំ ចេះអក្សរមានចំនួន ១,៥០៤ នាក់ ស្មើនឹង ៩៩.៣% (ភាគរយនេះមធ្យមដោយសារមានសិស្សជាច្រើនបានផ្ទេរទៅសិក្សានៅសាលាឯកជន និង សាលាផ្សេងៗ ក្នុងក្រុងកំពត) ។
- អត្រាអ្នកមិនចេះអក្សរអាយុពី១៥-៤៥ឆ្នាំមាន២.២%( ទិន្នន័យពីមន្ទីរផែនការខេត្តកំពតឆ្នាំ២០២៤)។

**បញ្ហាប្រឈមចំពោះមុខនៅក្នុងផ្នែកនេះរួមមាន៖**

- ឪពុកម្តាយមិនយល់ពីតម្លៃនៃការសិក្សា ទុកកូនឲ្យជួយការងាររកចំណូល
- ការចូលរួមពីអាណាព្យាបាលក៏ដូចជាមាតាបិតានៅមានកម្រិតមួយចំនួនបណ្តាលមកពីភាពក្រីក្រ ។
- កុមារមួយចំនួនកំព្រាឪពុកម្តាយខ្វះអ្នកជួយជំរុញ
- កង្វះអគារសិក្សានៅសាលាមួយចំនួន ។

### ១.២.២.២. ស្ថានភាពសុខាភិបាល

១. នៅទូទាំងស្រុក មានមណ្ឌលសុខភាពចំនួន ៩មណ្ឌល កំពុងបម្រើសេវាសុខភាពជូនប្រជាពលរដ្ឋ ។ ស្រុកបានជម្រុញឱ្យការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងមណ្ឌលសុខភាពផ្តល់សេវាសុខភាពជូនដល់ប្រជាពលរដ្ឋទូទាំងស្រុក រួមទាំងផ្តោតការយកចិត្តទុកដាក់ ជាពិសេស ដល់ប្រជាពលរដ្ឋក្រីក្រ មាតាទារក និងកុមារ សម្រេចបានលទ្ធផលដូចខាងក្រោម៖

- ផ្នែកពិគ្រោះជំងឺក្រៅ : ៣៣ ៨១៦ នាក់
- ផ្នែកពិនិត្យផ្ទៃពោះ : ៦៧៧៥ នាក់
- ផ្នែកពន្យាកំណើត : ៤០៣៩ នាក់
- ផ្នែកសម្រាលកូននៅមណ្ឌលសុខភាព : ៨០០ នាក់ សម្រាលតាមផ្ទះ: ០០ នាក់ សម្រាលដោយឆ្មបបុរាណ: ០០នាក់ សរុប: ៨០០នាក់
- ផ្នែកចាក់ថ្នាំបង្ការ : ១០ ២៣៩ នាក់ និងតេតាណូស ៤ ៣២៣ នាក់
- ផ្នែករបេង : ករណីថ្មី ២៤៦ នាក់ ១០១៩កំពុងព្យាបាល , អ្នកស្លាប់៨នាក់ ,

- ផ្នែកជម្ងឺគ្រុនចាញ់ : ០០ នាក់ បានចែកមុង ១៨១មុង ជ្រលក់មុង ២៧
- គ្រុនឈាមៈ ០០ នាក់៣៦៨១ (ក.គ)ដាក់អាបែត
- ផ្នែកអប់រំសុខភាពៈ ៥១១ នាក់
- ផ្នែកអាហារូបត្ថម្ភ ៖
  - ចំនួនកុមារទទួលវិតាមីនអាតាមភូមិៈ ១០៧០៦
  - ចំនួនកុមារទទួលវិតាមីនអាតាមសាលាៈ ២៥៦៥
  - កុមារទទួលមេបង់ដាសូលតាមភូមិៈ ១០០៧៧
  - កុមារទទួលមេបង់ដាសូលតាមសាលាៈ ៣៣៤៦៦នាក់

- ការធ្វើតេស្តរកមេរោគអេដស៍ៈ ១៥៥៨ករណី
- ការធ្វើតេស្តរកមេរោគស្វាយៈ ១៥៥៦ករណី
- ផ្តល់ជាតិដែកដល់ស្ត្រីមានផ្ទៃពោះ ២៥៩៤ករណី
- ផ្តល់ជាតិដែកសម្រាប់ព្យាបាលៈ ៦៥២ ករណី
- ចំនួនស្ត្រីដែលមកទទួលសេវារំលូតដោយសុវត្ថិភាព៖ ប្រើថ្នាំគ្រាប់ ១២៦ ករណីដោយប្រើឧបករណ៍ , បូមៈ ១២៣ ករណី សរុប ២៤៩ ករណី
- ស្ត្រីដែលមានអាយុ(៣០ដល់៤៩)ឆ្នាំ ពិនិត្យមហារីកមាត់ស្បូន ៩៩ករណី

- ការចាក់វ៉ាក់សាំងតាមមណ្ឌលក្នុងស្រុកទឹកឈូ ៖

- ដូសទី១: ៣២នាក់
- ដូសទី២: ០ នាក់,
- ដូសទី៣: ២៣នាក់
- ដូសទី៤: ១៧នាក់
- ដូសទី៥: ៩នាក់
- ដូសទី៦: ២ នាក់
- សរុបបានចំនួន៨៣នាក់ស្រី ៥៥ នាក់

**ទន្ទឹមនឹងការយកចិត្តទុកដាក់នេះក៏នៅមានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម ៖**

- ការគ្រប់គ្រងរបាយការណ៍រវាងសេវាសាធារណៈ សេវាឯកជន និងអង្គការមិនទាន់រលូន
- បុគ្គលិកចំនួន ចំណេះដឹង និង ជំនាញនៅមានកម្រិត
- ការយាមប្រចាំការនៅតាមមណ្ឌលសុខភាព នៅមានភាពខ្វះចន្លោះ
- ខ្វះបន្ទប់សម្រាកមុន និងក្រោយសំរាល
- ការពិគ្រោះជំងឺតាមយុទ្ធសាស្ត្រ ស.ព.ជ.ក លើកុមារអាយុក្រោម ៥ឆ្នាំ ពុំទាន់បានអនុវត្តគ្រប់មណ្ឌលសុខភាព។

**២. មរណៈភាពមាតា និងទារក**

សុខភាពមាតា និងទារក ជាចំណុចសំខាន់មួយដែលត្រូវការយកចិត្តដាក់ និងឆ្លុះបញ្ចាំងពីស្ថានភាពសុខភាពមាតា-ទារក ទាក់ទិននឹងការអប់រំសុខភាពសាធារណៈ

- ចំនួនមរណៈភាពទារកអាយុពី ០-១ខែក្នុងឆ្នាំ២០២៤ មាន ០០នាក់
- ចំនួនស្លាប់របស់កុមារក្រោម ០៥ឆ្នាំ មានចំនួន ០០នាក់

**បញ្ហាប្រឈមដែលកំពុងជួបប្រទះរួមមាន ៖**

- សេវាសង្គ្រោះបន្ទាន់(ជំងឺទូទៅសម្ភពទារក)នៅតាមមណ្ឌលសុខភាពគ្មាន(មណ្ឌល សុខភាពផ្ដល់សេវាបឋម)

- គុណភាពនៃការផ្ដល់សេវានៅមានកំរិត(សម្ថភាព ការប្រាស្រ័យទាក់ទង ពាក្យពេចន៍)

- កង្វះការយល់ដឹង និងភាពក្រីក្ររបស់ប្រជាពលរដ្ឋ

- ប្រជាពលរដ្ឋមួយចំនួនតូចនៅគោរពអបិយជំនឿ

- ការប្រើប្រាស់ថ្នាំបុរាណនៅតែមាន

- ការទទួលទានស្រាថ្នាំក្រោយសម្រាលនៅមានមួយភាគតូច

- ការមកទទួលសេវា ពិនិត្យសុខភាពនៅមានកម្រិត

- ការបំពេញការងារមិនបានជាប់លាប់ទាំងស្រុង

**៣. កំរិតទទួលបានសេវាសុខភាព និងអនាម័យទឹកស្អាត**

ការទទួលសេវាសុខភាពសាធារណៈ ពឹងផ្អែកលើគុណភាព នៃការផ្ដល់សេវាដល់ប្រជាពលរដ្ឋនិងការយល់ដឹងអំពីបញ្ហាសុខភាពទូទៅ ។ ជាមួយនេះទាមទារឲ្យស្រុកជំរុញដល់អ្នកពាក់ព័ន្ធបង្កើន ការផ្ដល់សេវាប្រកបដោយគុណភាពនិងសមធ៌ម រួមទាំងពង្រឹងបន្ថែមដល់ការផ្សព្វផ្សាយពី អនាម័យការប្រើប្រាស់ទឹកស្អាតបើទោះបីកន្លងមកស្រុកមានលទ្ធភាពផ្គត់ផ្គង់ទឹកស្អាតនៅទាបក៏ដោយ ។

**ជាមួយការអនុវត្តជាប្រចាំក៏មានបញ្ហាប្រឈម ដែលជួបប្រទះមួយចំនួនដូចជា៖**

- ខ្វះបុគ្គលិក និងធនធានផ្ដល់សេវា

- ការផ្សព្វផ្សាយពីវិធានការការពារជំងឺឆ្លង នៅតាមសហគមន៍ នៅមានកំរិត

- ប្រជាពលរដ្ឋខ្វះការយល់ពីសុខភាពអនាម័យ និងការប្រើប្រាស់ទឹកស្អាត

- ការផ្សព្វផ្សាយពីវិធានការក្នុងការការពារនៅមានកម្រិត

- ប្រជាពលរដ្ឋគ្មានលទ្ធភាព ក្នុងការសាងសង់បង្គន់អនាម័យ ឯការផ្គត់ផ្គង់មានកំរិត ។

**៤. គ្រោះថ្នាក់ និងជម្ងឺផ្សេងៗ** ទោះបីមានកិច្ចខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ មានបញ្ហាមួយចំនួនបានកើតដោយមិនអាចទប់ស្កាត់ និង វិធានការការពារមុនបានឡើយដូចជាៈ គ្រោះថ្នាក់ ចរាចរ ជម្ងឺដែលបណ្ដាលពីការរាតត្បាតនានា ដូចជាជម្ងឺកូវីដ១៩ កញ្ជ្រិល ស្អូច និងជម្ងឺតាមរដូវដូចជា គ្រុនឈាម គ្រុនចាញ់ ។ល។

**បញ្ហាប្រឈមទាំងនោះរួមមាន៖**

- គ្មានការឧបត្ថម្ភលើមធ្យោបាយទំនាក់ទំនង ពេលមានការរាតត្បាតនៃជំងឺឆ្លង

- ថវិកាសម្រាប់ដំណើរការអនុវត្តសកម្មភាពនូវមានកំរិត

- ការយល់ដឹងពីការបង្កាជំងឺឆ្លងរបស់មន្ត្រីសុខាភិបាលមួយចំនួនតូចនៅមានកំរិត ។

**១.២.២.៣. ស្ថានភាពយេនឌ័រ**

ស្រុកបានជម្រុញដល់វិស័យកិច្ចការនារី ឲ្យបន្តយកចិត្តទុកដាក់លើស្ថានភាពនៃការ ចូលរួមឱកាស និងការសម្រេចចិត្តរបស់ស្ត្រីក្នុងវិស័យនានារបស់សង្គម ។ជាមួយនោះផងដែរក៏បាន ផ្សព្វផ្សាយជាប្រចាំនូវច្បាប់ពាក់ព័ន្ធនានា សំដៅលើកកម្ពស់ការគោរពសិទ្ធិស្ត្រី និងកុមារ មានដូចជា៖

- ច្បាប់ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនងាយរងគ្រោះ

- កិច្ចការងារយេនឌ័រ

- ច្បាប់ទប់ស្កាត់ការជួញដូរមនុស្ស
- ការចំណាកស្រុកដោយប្រថុយប្រថាន
- អនុសញ្ញា ស៊ី.ដ(ប្រយុទ្ធប្រឆាំងចំពោះស្ត្រីភេទ)
- លើកកម្ពស់ស្ត្រី និងកុមារ
- លើកកម្ពស់អាហារូបត្ថម្ភ

ជាការពិតក្នុងពេលបច្ចុប្បន្នគេបានមើលឃើញពីការផ្លាស់ប្តូរទម្លាប់ និងឥរិយាបថ ដែលនឹងនាំស្ត្រីទៅដល់ការរួមចំណែកយ៉ាងធំធេង ក្នុងការចូលរួមរកប្រាក់ចំណូលក្នុងគ្រួសារ ក៏ដូចជាចូលរួម វិស័យនានារបស់សង្គម។ **ទន្ទឹមការខិតខំនេះក៏នៅតែមានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖**

- ការបែងចែកការងាររវាងបុរសស្ត្រីនៅមិនទាន់មានសមធម៌
- ការចូលរួមធ្វើសេចក្តីសម្រេចនៅមានកម្រិតទាប
- បន្ទុកគ្រួសារផ្ទះសម្បែងធ្លាក់លើស្ត្រីភាគច្រើន
- ចំណាកស្រុកទៅរកការងារធ្វើនៅតែបន្តមាន
- ទទួលរងអំពើហឹង្សាពីសំណាក់ប្តី

### ១.២.២.៤. ស្ថានភាពនៃភាពក្រីក្រ

បច្ចុប្បន្នភាពក្រីក្រជាបញ្ហាប្រឈមសម្រាប់ព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋាភិបាលបាននឹងកំពុងដំណើរការកសាងនិងអភិវឌ្ឍន៍ប្រទេសយ៉ាងសកម្មប្រកបដោយភាពជឿជាក់ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជានិតិកាលទី៧ នៃរដ្ឋសភា ។ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ កំពុង បានអនុវត្តដោយពេញលេញតាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០៣០ ដើម្បីជានាកំណើនការងារសមធម៌ និងប្រសិទ្ធភាពនៅកម្ពុជាក្នុងទិសដៅកាត់បន្ថយភាពក្រីក្រ របស់ ប្រជាពលរដ្ឋយ៉ាងតិច ១% ក្នុង១ឆ្នាំ និងកំណើនសេដ្ឋកិច្ច ៧% ក្នុង១ឆ្នាំ ។

ទន្ទឹមនឹងនេះដែរក៏មានបញ្ហាប្រឈមមួយចំនួន កំពុងកើតមានឡើងដូចជាបញ្ហាចំណាកស្រុកបញ្ហាបង្កើតការងារការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាចូលក្នុងសហគមន៍អាស៊ានដោយពេញលេញការប្រែប្រួលអាកាសធាតុពិសេសការខិតខំប្រឹងប្រែងអោយប្រទេសកម្ពុជា បានចាកចេញពីប្រទេស ដែលមានចំណូលទាបទៅកាន់ប្រទេសដែលមានចំណូលមធ្យម ។ ប្រការនេះបង្ហាញពីការខិតខំប្រឹង ប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រក្នុងល្បឿនមួយយ៉ាងឆាប់រហ័ស ។ ដោយឡែក តាមស្ថិតិរបស់មន្ទីរផែនការ (កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រមានចំនួន ៣៨៩០ គ្រួសារ គិតជាភាគរយ ១៨.២២% និងគ្រួសាររងហានិភ័យចំនួន ១៤១១ គ្រួសារ គិតជាភាគរយ ៦.៦១ % នៃគ្រួសារសរុបចំនួន ២៣,៣៨៣គ្រួសារ ។

**ក- មូលហេតុចម្បងៗ ដែលធ្វើឱ្យគ្រួសារមួយចំនួនធ្លាក់ខ្លួនក្រីក្រ**

- ការប្រព្រឹត្តអំពើអបាយមុខ ដូចជា ល្បែងស៊ីសង គ្រឿងញៀន
- មានអំពើហិង្សាក្នុងគ្រួសារ
- ជាប់បំណុល
- គ្មានដីស្រែបង្កបង្កើនផល (លក់កេរ្តិ៍អាករ)
- គ្មានមុខរបរពិតប្រាកដ

- គ្មានជំនាញពិតប្រាកដ

**ខ- មូលហេតុដែលគ្រួសារក្រីក្រមិនអាចកែលម្អជីវភាពរស់នៅឱ្យប្រសើរបានពីព្រោះ**

- ខ្វះចំណេះដឹង

- កង្វះខាតអាហារូបត្ថម្ភ ខ្វះអនាម័យ និងមិនសូវបានគិតគូអំពីវិធានការការពារ ច្រើនតែគិតគូពីការព្យាបាល ពោលគឺមិនយល់ដឹងពីមូលដ្ឋានក្នុងការថែទាំសុខភាព ។

- ភាពមិនខ្វល់ខ្វាយរស់នៅបានមួយថ្ងៃសម្រាប់តែមួយថ្ងៃគ្មានគោលដៅច្បាស់លាស់ក្នុងជីវិត ច្រើនគិតថាខ្លួនមិនអាចធ្វើអ្វីបានលើសពីនេះទេ មិនអាចកែប្រែស្ថានភាពឱ្យប្រសើរជាងនេះ គិតថាភាពក្រីក្រជាលក្ខខណ្ឌរបស់ខ្លួន។

- ភាពអាស្រ័យគេ មានគំនិតត្រឹមតែស៊ីឈ្នួលគេ គ្មានគំនិតច្នៃប្រឌិតក្នុងការរក។

- ភាពខ្ជះខ្ជាយ និងគ្មានការសន្សំសំចៃ មិនសូវឱ្យតម្លៃ និងការប្រើប្រាស់ធនធានដែលខ្លួនមានស្រាប់មិនសូវមានគំនិតច្នៃប្រឌិតក្នុងការបង្កើនចំណូល។

**គ- មូលហេតុដែលគ្រួសារក្រីក្រមួយចំនួនបានកែប្រែជីវភាពខ្លួនបាន**

- មានអាហារូបត្ថម្ភកាន់តែប្រសើរឡើងតាមរយៈការបង្កើនសកម្មភាពដាំដុះ

- មានការភ្ញាក់រលឹក យល់ដឹងពីអនាម័យ និងសុខភាព

- មានគំនិតច្នៃប្រឌិតមុខរបរប្រចាំថ្ងៃរបស់ពួកគាត់

- គ្មានអំពើហិង្សាក្នុងគ្រួសារ

- ស្វែងរក និងចូលរួមទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ

- មានការសន្សំសំចៃខ្ពស់ ។

### ១.២.២.៥. ស្ថានភាពសាសនាៈ

វិស័យធម្មការ និងសាសនាស្រុកបានសហការជាមួយមន្ត្រីសង្ឃ ស្ថាប័ននានាឲ្យបានល្អពង្រឹងសាលាពុទ្ធិកគ្រប់កំរិត និងលើកតម្លៃសីលធ៌មសង្គម ព្រមទាំងគណៈអ៊ីមុំា ស្រុកបានជម្រុញ លើកទឹកចិត្តប្រជាពលរដ្ឋបានបដិបត្តិជំនឿសាសនាតាមទស្សនៈរបស់សាសនិក ។

- ព្រះពុទ្ធសាសានាមាន ៣២ វត្ត(ក្នុងនោះធម្មយុត្តិ ៤វត្ត)

- ព្រះវិហារឥស្លាម ១៩ និងស៊ូរ៉ាវ ២២

- វិហារគ្រឹះសាសនា និងស្នាក់ការថ្វាយបង្គំ ៩កន្លែង

**បញ្ហាប្រឈមនៃស្ថានភាពសាសនារួមមាន៖**

- ការយល់ដឹងរបស់អាចារ្យ គណៈកម្មការនៅមានកម្រិតទាក់ទិនវិន័យធម៌

- ដណ្តើមតួនាទីគ្រប់គ្រងស៊ូរ៉ាវ(បំបែកស៊ូរ៉ាវ)

- គ្រូគង្វាលគ្រឹះសាសនាផ្សព្វផ្សាយមិនសហការជាមួយអាជ្ញាធរដែនដី ពិសេសមន្ត្រីជំនាញ

- សាសនិកឥស្លាមមួយចំនួនសាងសង់ស៊ូរ៉ាវដោយឥតគិតពីច្បាប់សាសនា និងរដ្ឋ

- សមណសិស្សចុះខ្សោយ

- ផ្នែកគ្រឹះសាសនាមួយចំនួន មិនសូវសហការជាមួយមន្ត្រីជំនាញ ។

### ១.២.២.៦. ស្ថានភាពអន្តោប្រវេសន៍ និងបំផ្លាស់ទីលំនៅ៖

ដោយស្ថានភាពភូមិសាស្ត្រធំទូលាយ អំណោយផលដល់ការរកស៊ីប្រកបមុខរបរចិញ្ចឹមជីវិត ធ្វើឲ្យបងប្អូនប្រជាពលរដ្ឋបានធ្វើចំណាកស្រុកពីតាមបណ្តាខេត្តផ្សេងៗ បានចូលមករស់នៅប្រកប មុខរបរផ្សេងៗមានដូចជា៖ រត់ម៉ូតូឌុប កម្មកររោងចក្រ រមណីយដ្ឋាន និងមានជនបរទេសចូលមក ប្រកបរបរ ដាំដំណាំចំការម្រេច ហាងលក់ដូរ ហាងអាហារ ។

**ទន្ទឹមនឹងនេះដែរស្រុកក៏នូវជួបបញ្ហាប្រឈមដូចជា៖**

- ការអនុវត្តច្បាប់អន្តោប្រវេសន៍នូវមានកម្រិត
- ដោយសារសកលលោកមានជម្ងឺកូវីដ ១៩ ដូចនេះការធ្វើចំណាកស្រុកចេញចូលរបស់ប្រជាពលរដ្ឋមួយចំនួនមិនបានជូនដំណឹងដល់អាជ្ញាធរ ធ្វើឲ្យពិបាកក្នុងការគ្រប់គ្រង

**១.២.២.៧. ស្ថានភាពផ្សេងៗ សម្រាប់សង្គមកិច្ច៖**

ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមពាក់ព័ន្ធវិស័យសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាមានដូចជា៖

| ល.រ | បរិយាយ | ចំនួនមុខសញ្ញា | ចំនួនបន្ទុក | ផ្សេងៗ |
|---|---|---|---|---|
| ១ | គ្រួសារផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ | ៩០ គ្រួសារ | | |
| ២ | ប្រជាជនទីទ័លក្រប្រភេទ ១ | ១,០៣១គ្រួសារ | | |
| ៣ | ប្រជាជនទីទ័លក្រប្រភេទ ២ | ២,៨៥៩គ្រួសារ | | |
| ៤ | គ្រួសារងាយរងហានិភ័យ | ១,៤១១គ្រួសារ | | |
| ៥ | ប្រជាជនរងគ្រោះដោយធម្មជាតិ | ២៥៦ គ្រួសារ | | |
| ៦ | កុមារផ្ទុកមេរោគអេដស៍ | ២៦នាក់ | | |
| ៧ | និវត្តជន | ៣១៤នាក់ | | |
| ៨ | ជនបាត់បង់សម្បទាវិជ្ជាជីវៈ | ៣០នាក់ | | |
| ៩ | បន្ទុកសពនិវត្តជន | ១០១ នាក់ | | |
| ១០ | បន្ទុកសពជនបាត់បង់សម្បទាវិជ្ជាជីវៈ | ៣៤ នាក់ | | |
| ១១ | ជនពិការ(ប.ជ.អ) | ១៩៨ នាក់ | | |
| ១២ | និវត្តជន(ប.ជ.អ) | ២២៨នាក់ | | |
| ១៣ | ជនបាត់បង់សមត្ថភាពការងារ(ប.ជ.អ) | ០៥នាក់ | | |
| ១៤ | គ្រួសារពលី(ប.ជ.អ) | ២៤៤នាក់ | | |
| ១៥ | គ្រួសារមរណៈ(ប.ជ.អ) | ៦៩ នាក់ | | |

ប្រជាជនទីទ័លក្រ ជនរងគ្រោះ និងជនងាយរងគ្រោះមួយចំនួនក្នុងស្រុក បានទទួលសេវាសង្គមកិច្ចជាលក្ខណៈជំនួយមនុស្សធម៌ពុំទាន់មានបេឡាជាតិសន្តិសុខសង្គមនិងខ្វះការគាំទ្រក្នុងការផ្តល់សេវា ពីមន្ទីរសង្គមកិច្ចអតីត យុទ្ធជននិងយុវនីតិសម្បទា មន្ទីរកិច្ចការនារី កាកបាទក្រហមខេត្ត អនុសាខាកាកបាទក្រហមស្រុក អង្គការសប្បុរសជន និងសហគមន៍ឡើយ ។

ការិយាល័យសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទាបានផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍន៍សង្គមមនុស្សតែទោះជាយ៉ាងណាក៏នៅមានបញ្ហាប្រឈមមួយចំនួនកើតមាន ៖

- ប្រជាជនទីទ័លក្រ មានដីបន្តិចបន្តួចខ្វះជំនាញ គ្មានមុខរបរ មិនឧស្សាហ៍ព្យាយាម

- ជនវិកលចរិក និង ជនអនាថាមិនទាន់ដោះស្រាយនៅឡើយ

- ជនពិការមួយចំនួនមិនទាន់បានស្តារកាយសម្បទា/ស្តារសតិបញ្ញា

- ជនពិការភាគច្រើនគ្មានជំនាញ និងមុខរបរ

- មានកំណើនជនពិការក្នុងមនុស្សចាស់

- ពុំទាន់បានរៀបចំច្រកចេញចូលសំរាប់ជនពិការគ្រប់ប្រភេទ

- អ្នកជំងឺអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍ ជាទូទៅជួបការលំបាកអំពីជីវភាពរស់នៅប្រចាំថ្ងៃនិងការថែទាំសុខភាព។

- ជនចាស់ជរាមួយចំនួនមានជម្ងឺផ្លូវចិត្ត និងជួបការលំបាកបញ្ហាជីវភាព

- កំណើនមនុស្សចាស់ក៏ជាបញ្ហាមួយត្រូវយកចិត្តទុកដាក់

- ជនរងគ្រោះនិងជនងាយរងគ្រោះមានបញ្ហាខ្វះជំរក ខ្វះស្បៀងអាហារ ខ្វះដីសម្រាប់សង់លំនៅដ្ឋាន

- ដោយសារបញ្ញារីករាលដាលដោយជំងឺ បង្កដោយមេរោគកូវីដ១៩ ការមកទទួលសេវាអតិថិជនមានការភ័យខ្លាចក្នុងការមកមណ្ឌលសុខភាព ហើយសូចនាករមួយចំនួនធ្លាក់ចុះ

- ប្រជាជនភាគច្រើនដែលមានលទ្ធភាពច្រើនទៅទទួលសេវានៅគ្លីនិចឯកជន

- មុខសញ្ញាភាគច្រើនជួបការលំបាកបញ្ហាជីវភាព

## ១.២.៣.ស្ថានភាពធនធានធម្មជាតិ បរិស្ថាន និងការបន្សាំ នឹងការប្រែប្រួលអាកាសធាតុ

### ១.២.៣.១.ការប្រើប្រាស់ដីធ្លី

ចែកចេញជាដីសាងសង់ ដីផលិតកម្មកសិកម្ម តំបន់អភិរក្សព្រៃឈើនៅលាយឡំគ្នាមិនទាន់បានចុះធ្វើអត្តសញ្ញាណកម្មនៅឡើយ ។ប៉ុន្តែដើម្បីប្រើប្រាស់ដីធ្លីឲ្យបានសមស្រប ស្រុកបានជម្រុញការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុក ក្នុងការធ្វើចំណាត់ថ្នាក់ដីដើម្បីផ្តល់ កម្មសិទ្ធិជូនប្រជាពលរដ្ឋ និងចំណាត់ប្រភេទដីរដ្ឋសម្រួលដល់ការគ្រប់គ្រង និងកាត់បន្ថយភាពក្រីក្រ ។

**ប៉ុន្តែទោះបីមានការខិតខំពីអាជ្ញាធរគ្រប់ជាន់ថ្នាក់យ៉ាងណាក៏ដោយក៏នៅជួបបញ្ហាប្រឈមជាច្រើនដូចជា៖**

- ប្រជាពលរដ្ឋពុំទាន់បានយល់ដឹងពីច្បាប់ភូមិបាល

- ការទន្ទ្រានកាន់កាប់ដីរដ្ឋ

- ការសាងសង់សំណង់លើដីរដ្ឋ

- សាងសង់សំណង់គ្មានច្បាប់អនុញ្ញាតិ

- បញ្ហាទំនាស់ដីធ្លីនៅតែមាន

### ១.២.៣.២. ការគ្រប់គ្រងធនធានធម្មជាតិៈ

នៅក្នុងស្រុកទឹកឈូ មួយផ្នែកគ្របដណ្តប់ដោយព្រៃឈើ និងមួយផ្នែកទៀតគ្របដណ្តប់ដោយព្រៃលិចទឹកជាជំរកមច្ឆាជាតិ ដែលជាសក្តានុពលជួយដល់កំណើនសេដ្ឋកិច្ចក្នុងស្រុកលើវិស័យជល ផលផងដែរ ។

**ទន្ទឹមនឹងសក្តានុពលដែលមានសំបូរបែបក៏មានបញ្ហាប្រឈមមួយចំនួនកំពុងធ្វើឲ្យមានការប៉ះពាល់ដូចជា**

- ប្រជាពលរដ្ឋមួយចំនួនតូចមិនអនុវត្តន៍ច្បាប់ព្រៃឈើ

- មានការកាប់បំផ្លាញព្រៃឈើ ដើម្បីទន្ទ្រានយកដី

- ចាក់ដីលុបតាមតំបន់ឆ្នេរ ធ្វើដីកម្មសិទ្ធិ បាត់បង់ជម្រកសម្រាប់មច្ឆាពង កូន

- ពុំទាន់មានការកំណត់ព្រំប្រទល់ព្រៃឈើច្បាស់លាស់

### ១.២.៣.៣. បរិស្ថាន

ការគ្រប់គ្រងសំណល់រឹង រាវ សំលេង ផ្សែង រំញ័រ គឺជាផ្នែកមួយជួយទប់ស្កាត់ដល់ការបំពុលបរិយាកាស និងការប្រែប្រួលអាកាសធាតុ ដែលកំពុងបង្កឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ពីមួយឆ្នាំ ទៅមួយឆ្នាំ ដូចជា ការកើនឡើងរលកកំដៅ ភាពរាំងស្ងួតអូសបន្លាយ រយៈពេលវែង ខ្យល់ព្យុះទឹកជំនន់រន្ទះបាញ់ជាដើម..ល។កត្តាដែលធ្វើអោយមានការប្រែប្រួលអាកាសធាតុ យ៉ាងឆាប់រហ័សនេះគឺតាមរយៈសកម្មភាពជាច្រើនដែលបង្កឡើងដោយសារមនុស្សរស់នលើផែនដីដែលបាននឹងកំពុងបំផ្លាញបរិស្ថានគ្រប់រូបភាព។រដ្ឋបាលស្រុកបានជម្រុញក្នុងការផ្សព្វផ្សាយកាកសំណល់រឹងនៅតាមទីប្រជុំជន និងតំបន់ទេសចរ ព្រមទាំងមានកិច្ចសហការជាមួយមន្ទីរបរិស្ថាន និងស្ថាប័នពាក់ព័ន្ធផ្សេងៗចូលរួមថែរក្សា និងការពារបរិស្ថាន ដើម្បីរក្សាលំនឹងស្ថេរភាពបរិស្ថាន សម្រាប់ជីវិតមនុស្ស សត្វទូទាំងស្រុក ។

ទន្ទឹមនឹងការខិតខំ ក៏មានបញ្ហាប្រឈមមួយចំនួនផងដែរ ដូចជា៖

- មិនបានធ្វើការអប់រំផ្សព្វផ្សាយច្បាប់បរិស្ថានតាមរយៈផ្ទាំងប៉ាណូ
- មិនបានផ្សព្វផ្សាយតាមរយៈការប្រជុំផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំលេង ផ្សែង រំញ័រ
- ការបង្ហូរលាមកសត្វចេញពីកសិដ្ឋាន បង្កឲ្យប៉ះពាល់សុខភាព និងខូចប្រភពទឹក ប្រើប្រាស់
- មានការអនុញ្ញាតិពីមន្ត្រីជំនាញមួយចំនួន ធ្វើការចិញ្ចឹមសត្វជាលក្ខណៈអាជីវកម្មនៅបង្ករអោយមានក្លិនស្អុយ និងសំលេងរំខាន់
- ការបោះចោលសំរាមពាសវាលពាសកាល និងការដុតសំរាម
- ការគ្រប់គ្រងសំរាមមិនមានលក្ខណៈបច្ចេកទេស
- តាមបណ្តាឃុំមិនទាន់មានទីលានសម្រាប់ចាក់សំរាម
- ការចោលសំណល់ប្រើប្រាស់ដូចជា ថ្មពិលចាស់ៗ សំណល់វេជ្ជសាស្ត្រ សំណល់ អាគុយ សំណល់គ្រឿងអេឡិចត្រូនិច ឧស្ម័នផ្ទះកញ្ចក់ ប្រេងម៉ាស៊ីន។ល។

កត្តាទាំងអស់នេះមានផលប៉ះពាល់ដល់សុខភាពមនុស្ស សត្វ និងបរិយាកាស រួមទាំងមានផលប៉ះពាល់បរិស្ថាន និងការបម្រែបម្រួលអាកាសធាតុ ។

### ១.២.៣.៤. ការគ្រប់គ្រងគ្រោះមហន្តរាយៈ

គ្រោះថ្នាក់ធម្មជាតិដូចជា ទឹកជំនន់ ការរាំងស្ងួត ខ្យល់ព្យុះ ការរាតត្បាតនៃជំងឺនានា ដែល បានជួបប្រទះកន្លងមកបានបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្សសត្វ ការបំផ្លាញផលដំណាំកសិកម្ម ទ្រព្យ សម្បត្តិរបស់ប្រជាជន និងប៉ះពាល់ដល់សេដ្ឋកិច្ចក្នុងស្រុកផងដែរ ។ ដើម្បីត្រៀមបង្ការទប់ទល់នឹង គ្រោះមហន្តរាយដោយធម្មជាតិទាំងនោះ ស្រុកបានកែសម្រួលគណៈកម្មាធិកាគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក (តាមការណែនាំរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ) នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ មាន រចនាសម្ព័ន្ធគ្រប់គ្រងចាប់ពីថ្នាក់ស្រុក-ដល់ឃុំ និងរៀបចំក្រុមគ្រប់គ្រងគ្រោះមហន្តរាយនៅតាមភូមិ ។

ស្រុកបានយកចិត្តទុកដាក់លើការងារនេះ ក្នុងនោះគណៈកម្មាធិកាគ្រប់គ្រងគ្រោះមហន្តរាយ បានរៀបចំផែនការ គោលការណ៍ ណែនាំដល់អាជ្ញាធរដែនដីគ្រប់ថ្នាក់ គណៈកម្មាធិការគ្រប់គ្រងគ្រោះ មហន្តរាយថ្នាក់ស្រុក ឃុំ និងក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយភូមិ បន្តយកចិត្តទុកដាក់ត្រៀមបង្ការ ជាមុនជានដល់ការសង្គ្រោះបន្ទាន់នៅពេលមានគ្រោះធម្មជាតិកើតឡើង។ទន្ទឹមនឹងនោះគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកបានរៀបចំលិខិតបទដ្ឋានគតិយុត្តនានាដើម្បីឆ្លើយតបរួមទាំង ទប់ទល់ និងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ លិខិតទាំងនោះរួមមាន៖

- សេចក្តីសំរេចបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក
- សេចក្តីសំរេចបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ ភូមិ

**នៅក្នុងឆ្នាំ២០២៤ កន្លងមកទូទាំងស្រុកមានករណីគ្រោះមហន្តរាយដូចជា៖**

- គ្រោះថ្នាក់លង់ទឹកស្លាប់ចំនួន ០៤ នាក់ ស្រី ០២ នាក់
- ភ្លើងឆេះផ្ទះចំនួន ០៣ ខ្នង
- ខ្យល់កន្ត្រាក់ខូចខាតផ្ទះប្រជាពលរដ្ឋចំនួន ២៥៣ គ្រួសារ

## ១.២.៤. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និង សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

### ១.២.៤.១ អភិបាលកិច្ច

ស្រុកបានបន្តយកចិត្តទុកដាក់អនុវត្ត តាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ ប្រជាពលរដ្ឋដោយផ្អែកលើគោលការណ៍៖

- កាត់បន្ថយយ៉ាងតិចពាក់កណ្តាលនូវសមាមាត្រនៃបុរសស្ត្រីនិងកុមារគ្រប់អាយុដែលរស់នៅក្នុងភាពក្រីក្រគ្រប់សមាសភាពដោយផ្អែកលើនិយមន័យរបស់កម្ពុជានៅត្រឹមឆ្នាំ២០២៤។
- អនុវត្តប្រព័ន្ធជាតិគាំពារសង្គម និងវិធានការផ្សេងៗទៀតឲ្យបានទូទាំងប្រទេស និងសម្រេចបានភាគច្រើននូវភាពគ្របឌណ្តប់នៃប្រព័ន្ធនេះដល់ប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះ ។
- ធានាថាបុរស ស្ត្រីគ្រប់រូបជាពិសេសប្រជាជនក្រីក្រ និង ប្រជាជនងាយរងគ្រោះ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ធនធានសេដ្ឋកិច្ច និងក្នុងការទទួលសេវាមូលដ្ឋាន ភាពជាម្ចាស់និងការគ្រប់គ្រងដីកម្មសិទ្ធិផ្សេងៗធនធានធម្មជាតិ បច្ចេកវិទ្យាថ្មីៗសមស្រប និងសេវាហិរញ្ញវត្ថុ រួមទាំងមីក្រូហិរញ្ញវត្ថុ។
- ការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព និងអភិបាលកិច្ចល្អជាស្នូល
- លើកទឹកចិត្តទាក់ទាញវិនិយោគិនពីក្នុង និងក្រៅស្រុកឲ្យបានច្រើនបន្ថែមទៀត ដែលបច្ចុប្បន្នកំពុងធ្វើការប្រមូលផ្តុំទៅលើវិស័យកសិកម្ម ដែលជាជ្រុងមួយនៃយុទ្ធសាស្ត្របញ្ច កោណរបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសយកចិត្តទុកដាក់ការងារផលិតដំណាំស្រូវ និង ដំណាំរួមផ្សំផ្សេងៗទៀត ដំណាំម្រេច ដែលជាតំរូវការចាំបាច់សម្រាប់នាំចេញ និងការ ផលិតអំបិលដែលជាជម្រើសអាទិភាពចំពោះមុខ ។ ប៉ុន្តែស្រុកចាត់ទុកថាវិស័យផ្សេងៗ ទៀត ត្រូវធ្វើការអភិវឌ្ឍឲ្យកាន់តែខ្លាំង ដើម្បីជាកំលាំងចលករជំរុញខឿនសេដ្ឋកិច្ច សង្គមកិច្ច របស់ស្រុកមានសន្ទុស្សន៍កើនឡើងយ៉ាងឆាប់រហ័ស ឆ្ពោះទៅរកភាពសុខដុមនីយកម្ម និង សង្គតិភាព លើកកំពស់ជីវភាពរស់នៅសម្រាប់ប្រជាពលរដ្ឋឱ្យបានល្អប្រសើរ ។
- យើងសង្កេតឃើញថាសភាពការណ៍នយោបាយសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ដូចជាជីវភាពសេដ្ឋកិច្ច របស់ប្រជាពលរដ្ឋ មានស្ថានភាពល្អ និងមានការអភិវឌ្ឍន៍ ជា បន្តបន្ទាប់ នេះអាស្រ័យដោយមានការចង្អុលបង្ហាញណែនាំពីក្រសួងមហាផ្ទៃ និងអាជ្ញាធរស្រុក បានធ្វើការសហការជាមួយស្ថាប័នពាក់ព័ន្ធ និង អង្គភាពក្រោមឪវាទរៀបចំរចនា សម្ព័ន្ធការពារសន្តិសុខសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋនៅមូលដ្ឋានទូទាំងស្រុក ពិសេសយើងបានបំផុសចលនាទូលំទូលាយ ក្នុងការអនុវត្តគោលនយោបាយ ភូមិឃុំ មានសុវត្ថិភាព មាន ០៧ចំនុចសំខាន់ៗគឺ ៖
- ផ្តល់សេវាសាធារណៈជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាពតម្លាភាព និងទទួលបានជំនឿទុកចិត្ត

- គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
- មានសណ្ដាប់ធ្នាប់សាធារណៈល្អ ពិសេសគ្មានគ្រោះថ្នាក់ចរាចរ
- គ្មានអំពើអាណាចារ គ្មានការជួញដូរមនុស្សពិសេសស្ត្រី និងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង
- ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និង ប្រសិទ្ធភាព
- មានអនាម័យ មានសោភ័ណ្ឌភាពល្អ និងមានបរិស្ថានល្អ
- ការឆ្លើយតបទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធិភាព ។

